គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ:...៤៥៩.ល.ស.../គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី..២៣. ខែ..ធ.ន.. ឆ្នាំ២០១៦

សូមគោរពជូន
ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ
និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

<u>កម្មវត្ថុ</u>: ការរៀបចំតាក់តែងកម្មវិធីជំនួយសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា ផ្អែកតាមកម្មវិធីប៉ាន់ស្មានថវិកាជំនួយពហុឆ្នាំពីសហភាពអឺរ៉ុប (Multi-Annual Indicative Program-MIP) ដល់រាជរដ្ឋាភិបាលកម្ពុជាលើគ្រប់វិស័យសម្រាប់ឆ្នាំ២០១៤-២០២០ ដែលមានទឹកប្រាក់សរុបប្រមាណ**៤០០** លានអឺរ៉ូ សហភាពអឺរ៉ុបបានគ្រោងថវិកាចំនួនប្រមាណ**៥០**លានអឺរ៉ូ (ប្រមាណ**៥៧**លានដុល្លារអាមេរិក) សម្រាប់គាំទ្រដល់កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ផ្អែកលើកម្មវិធីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប កំពុងសហការជាមួយក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហភាពអឺរ៉ុបក្នុងការរៀបចំតាក់តែងកម្មវិធីនេះដើម្បីធានាថា អាចទទួលបានការផ្តល់ហិរញ្ញប្បទានជំនួយនេះសម្រាប់គាំទ្រកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០១៧តទៅ។ យោងតាមការពិភាក្សាជាបន្តបន្ទាប់ ក្រុមការងារបានពិចារណាទៅលើការបែងចែកនូវ**ចីរភាព** **ទំហំថវិកា** និង**សមាសភាគ**សំខាន់ៗនានានៃកម្មវិធីដែលត្រូវរៀបចំតាក់តែងឡើងដោយផ្អែកតាមការប្រមើលមើលពីស្ថានភាពវិត្តជាក់ស្តែងនៃកំណែទម្រង់។

ជាទូទៅ មន្ត្រីសហភាពអឺរ៉ុបមានបំណងស្វែងយល់អំពីជំហរបស់រាជរដ្ឋាភិបាល (គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ពាក់ព័ន្ធនឹងចំណុចសំខាន់ៗទាំងបីខាងលើនេះ ដើម្បីធានាថា ការរៀបចំកម្មវិធីនេះមានលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់កម្ពុជា ហើយក៏អាចធានាដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់ទីចាត់ការកណ្តាលនៃសហភាពអឺរ៉ុបផងដែរ។ មានន័យថា **ចីរភាព**នៃកម្មវិធីអាចកំណត់ត្រឹមឆ្នាំ២០២០ ឬអាចពន្យារប៉ុន្មានឆ្នាំបន្ថែមទៀត ហើយ**ទំហំថវិកា**ក៏អាចប្រើប្រាស់ទាំងអស់តែម្តងរហូតដល់ឆ្នាំ២០២០ ឬ**អាចរក្សាទុកមួយចំនួន**សម្រាប់ការពន្យារពេលប៉ុន្មានឆ្នាំបន្ថែមទៀត។ ដោយឡែក កម្មវិធីនេះចាំបាច់ត្រូវផ្តោតទៅលើ**សមាសភាគ**សំខាន់ៗ**ចំនួន៣** ពោលគឺ **ការគាំទ្រសកម្មភាពស្នូល**នៃកម្មវិធីកំណែទម្រង់ **ការគាំទ្រមូលនិធិក្រុង ស្រុក** និងការគាំទ្រ**ក្នុងលក្ខណៈជាវិធានការបំពេញបន្ថែម** (Complementary Measures)។ ការផ្តល់ហិរញ្ញប្បទានពីសហភាពអឺរ៉ុបចំពោះសមាសភាគ២ខាងដើមនឹងត្រូវអនុវត្តតាម**បែបផែននៃការទ្រទ្រង់ដល់ថវិការដ្ឋ** (Budget Support Modality) ដោយឡែកការគាំទ្រក្នុងលក្ខណៈជាវិធានការបំពេញបន្ថែមនឹងត្រូវផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ពីសហភាពអឺរ៉ុបទៅ

ឱ្យគម្រោង ឬកម្មវិធីរបស់ភ្នាក់ងារអនុវត្តណាមួយ។

នៅក្នុងការគាំទ្រតាមបែបផែននៃ**ការទ្រទ្រង់ដល់ថវិការដ្ឋ** សហភាពអឺរ៉ុបនឹងផ្តល់ថវិកាសម្រាប់គាំទ្រកំណែទម្រង់ទៅឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបន្តផ្ទេរមកឱ្យលេខាធិការដ្ឋាន គ.ជ.អ.បដោយផ្អែកទៅតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនីមួយៗដែល គ.ជ.អ.ប បានអនុម័ត។ បែបផែនថ្មីនេះតម្រូវឱ្យរាជរដ្ឋាភិបាលធានាថា ការផ្ទេរថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមកស្ថាប័នអនុវត្ត ត្រូវអនុវត្តយ៉ាងទាន់ពេលវេលា និងមានប្រសិទ្ធភាពតាមប្រព័ន្ធរបស់រាជរដ្ឋាភិបាល។ លក្ខខណ្ឌចាំបាច់របស់សហភាពអឺរ៉ុបក្នុងការផ្តល់ហិរញ្ញប្បទានប្រចាំឆ្នាំនីមួយៗ គឺការសម្រេចបាននូវសូចនាករសំខាន់ៗប្រមាណចំនួន ១០ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការកំណែទម្រង់ (សូចនាករទាំងនេះត្រូវមានការឯកភាពគ្នាជាមុនរវាងរាជរដ្ឋាភិបាល និងសហភាពអឺរ៉ុប)។ ក្នុងករណីដែលសូចនាករណាមួយមិនបានសម្រេច នោះសហភាពអឺរ៉ុបនឹងមិនផ្តល់ហិរញ្ញប្បទានដែលពាក់ព័ន្ធទៅនឹងការអនុវត្ត សូចនាកររនោះឡើយ។ បែបផែននេះត្រូវបានសម្រេចជាគោលការណ៍ដោយសហភាពអឺរ៉ុបទៅលើរាល់ការរៀបចំកម្មវិធីគាំទ្រដល់វិស័យទាំងឡាយសម្រាប់កម្ពុជា។ ពាក់ព័ន្ធនឹងការគាំទ្រតាមបែបផែនថ្មីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានជួបពិភាក្សាជាមួយនឹងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនាពេលកន្លងមកដើម្បីស្វែងរកវិធានការចាំបាច់មួយចំនួនដែលចាំបាច់ត្រូវស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីធានាដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលជាការព្រួយបារម្ភរបស់សហភាពអឺរ៉ុប និងលេខាធិការដ្ឋាន គ.ជ.អ.ប ពោលគឺការធានានូវការទម្លាក់ថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ព្រមទាំងការចំណាយទៅលើជំនួយបច្ចេកទេស ដែលនៅចាំបាច់ត្រូវការចំណាយថវិកាដ៏ធំមួយ។

ជារួម សហភាពអឺរ៉ុបនឹងក្លាយទៅជាដៃគូដ៏សំខាន់ចាប់ពីឆ្នាំ២០១៧តទៅក្នុងចំណោមដៃគូទាំង ៣ (EU Sida និងSDC) ដែលកំពុងជួយគាំទ្រដល់សកម្មភាពស្នូលនៃកម្មវិធីកំណែទម្រង់ក្នុងបែបផែនជាថវិកាកញ្ចប់រួម។ ក្នុងន័យនេះ ការរៀបចំកម្មវិធីគាំទ្ររបស់សហភាពអឺរ៉ុបនឹងគ្របដណ្តប់ទៅលើការធានាឱ្យមានការគាំទ្រយ៉ាងធំធេងទៅលើទាំងជំនួយបច្ចេកទេស និងកិច្ចប្រតិបត្តិការទាំងឡាយនៃកម្មវិធីកំណែទម្រង់នាពេលអនាគតយូរអង្វែង។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បាន និងកំពុងរៀបចំស្នើសុំសហភាពអឺរ៉ុបក្នុងការរៀបចំកម្មវិធីគាំទ្ររបស់ខ្លួនដូចខាងក្រោម៖

១. អំពីចិរវេលានៃកម្មវិធី៖

ទោះបីជាកម្មវិធីប៉ាន់ស្មានថវិកាពហុឆ្នាំដែលគាំទ្រពីសហភាពអឺរ៉ុបគ្របដណ្តប់លើចិរវេលារហូតត្រឹមឆ្នាំ២០២០ក៏ដោយ ក៏ប៉ុន្តែដើម្បីធានាដល់ការរៀបចំកម្មវិធីបន្តគាំទ្រថ្មីពីឆ្នាំ២០២០ទៅបណ្តាឆ្នាំខាងមុខទៀត លេខាធិការដ្ឋាន គ.ជ.អ.ប បានគ្រោងស្នើសុំសហភាពអឺរ៉ុបក្នុងការបែងចែកចិរវេលានៃកម្មវិធីជា ២ដំណាក់កាលដូចខាងក្រោម៖

- ដំណាក់កាលទី១ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០
- ដំណាក់កាលទី២ពីឆ្នាំ២០២០ដល់ឆ្នាំ២០២១

ការរៀបចំឱ្យមានដំណាក់កាលទី២រយៈពេល២ឆ្នាំនេះ មានគោលបំណងដើម្បីធានាដល់ការតភ្ជាប់នូវការគាំទ្ររបស់សហភាពអឺរ៉ុបចាប់ពីឆ្នាំ២០២០តទៅ ក្នុងករណីដែលការរៀបចំតាក់តែងកម្មវិធីប៉ាន់ស្មានថវិកាជំនួយពហុឆ្នាំដំណាក់កាលបន្ទាប់មានភាពយឺតយ៉ាវក្នុងការសម្រេចដូចធ្លាប់បានកើតឡើងនៅក្នុង

ដំណាក់កាលទី១នាពេលកន្លងមកនេះ (កម្មវិធីនេះមានថវិការគ្របដណ្តប់ពីឆ្នាំ២០១៤ដល់ឆ្នាំ២០២០ ប៉ុន្តែទើបតែបានចុះហត្ថលេខាជាមួយគ្នានៅចុងឆ្នាំ២០១៥)។

២. អំពីការគ្រោងថវិកាកម្មវិធី៖

ផ្អែកលើការបែងចែកជាដំណាក់កាល និងតម្រូវការថវិកាសម្រាប់សមាសភាគសំខាន់ៗដូចដែលបានគូសបញ្ជាក់ខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប បានគ្រោងស្នើថវិកាសម្រាប់កម្មវិធីដូចខាងក្រោម៖

- ដំណាក់កាលទី១ មានចំនួន**៤៧លាន**ដុល្លារអាមេរិក
- ដំណាក់កាលទី២ មានចំនួន**១០លាន**ដុល្លារអាមេរិក

ការគ្រោងស្នើថវិកាចំនួន**១០លាន**ដុល្លារសម្រាប់ដំណាក់កាលទី២ មានគោលបំណងធានាលទ្ធភាពដល់ការបំពេញបន្ថែមនូវថវិកាសម្រាប់ឆ្នាំ២០២០ (ក្នុងករណីមានភាពចាំបាច់ក្នុងការបំពេញបន្ថែម) និងការគ្រោងថវិកាសម្រាប់ឆ្នាំ២០២១ ក្នុងករណីដែលកម្មវិធីប៉ាន់ស្មានថវិកាជំនួយពហុឆ្នាំថ្មីមិនអាចសម្រេចបានទាន់ពេលវេលា។

៣.អំពីសមាសភាគនៃកម្មវិធី និងថវិកាសម្រាប់សមាសភាគនីមួយៗ៖

សមាភាគដែលចាំបាច់របស់កម្មវិធីនេះមានចំនួន៣ ដែលគ្រោងស្នើសុំឱ្យសហភាពអឺរ៉ុបគាំទ្រថវិកាសរុបចំនួនប្រមាណ**៤៧លាន**ដុល្លារ តាមរយៈការរៀបចំកម្មវិធីនេះដូចខាងក្រោម៖

ក. ការគាំទ្រសកម្មភាពស្នូលនៃកម្មវិធីកំណែទម្រង់ គ្រោងថវិកាចំនួនប្រមាណ**២៩លាន**ដុល្លារ

ខ. ការគាំទ្រមូលនិធិក្រុង ស្រុក គ្រោងថវិកាចំនួនប្រមាណ**១២លាន**ដុល្លារ និង

គ. ការគាំទ្រក្នុងលក្ខណៈជាវិធានការបំពេញបន្ថែម គ្រោងថវិកាប្រមាណ**៦លាន**ដុល្លារ

- **ការគាំទ្រសកម្មភាពស្នូលនៃកម្មវិធីកំណែទម្រង់**មានចំនួន**២៩**លានដុល្លារ។ ថវិកានេះ គ្រោងបែងចែកតាមបណ្តាឆ្នាំនានាដូចខាងក្រោម៖
  - ✓ ឆ្នាំ២០១៧មានចំនួនប្រមាណ**៩លាន**ដុល្លារ
  - ✓ ឆ្នាំ២០១៨មានចំនួនប្រមាណ**៧លាន**ដុល្លារ
  - ✓ ឆ្នាំ២០១៩មានចំនួនប្រមាណ**៧លាន**ដុល្លារ
  - ✓ ឆ្នាំ២០២០មានចំនួនប្រមាណ**៦លាន**ដុល្លារ

សំណើបែងចែកថវិកាដែលមានចំនួនច្រើនក្នុងឆ្នាំទី១នៃកម្មវិធី ដោយហេតុថា ក្នុងឆ្នាំ២០១៦នេះដៃគូ២ផ្សេងទៀត(SidaនិងSDC)បានអនុញ្ញាតឱ្យប្រើប្រាស់ថវិការបស់ខ្លួនដែលគ្រោងសម្រាប់ឆ្នាំ២០១៧មកប្រើប្រាស់នៅក្នុងឆ្នាំ២០១៦ ដោយសារពុំមានថវិកាគាំទ្រពីសហភាពអឺរ៉ុប។ អាស្រ័យហេតុនេះ នៅឆ្នាំ២០១៧ ចាំបាច់ត្រូវប្រើប្រាស់ថវិការបស់សហភាពអឺរ៉ុប ដើម្បីធានាដល់ការគាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ក្នុងទំហំថវិកាមួយសមស្រប។

- **ការគាំទ្រមូលនិធិក្រុង ស្រុក** មានចំនួន**១២លាន**ដុល្លារ

ផ្អែកលើសារសំខាន់នៃរដ្ឋបាលក្រុង ស្រុកដែលនឹងក្លាយទៅជារដ្ឋបាលមូលដ្ឋានដ៏សំខាន់នៅក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន រាជរដ្ឋាភិបាល តាមរយៈផអ៣ទី២បានកំណត់អំពីការបង្កើនអត្រាភាគរយនៃថវិកាសមាសភាគអភិវឌ្ឍមូលដ្ឋានរបស់មូលនិធិក្រុង ស្រុកឱ្យបានយ៉ាងតិច**0,៥%** នៅឆ្នាំ២០១៨ធៀបនឹងចំណូលចរន្តសរុបនៃថវិកាជាតិប្រចាំឆ្នាំមុន។ ជាមួយគ្នានេះដែរ ក្នុងក្របខ័ណ្ឌនៃ

ផអ៣ទី២ យើងក៏បានគ្រោងស្នើសុំឱ្យមានការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ ជាពិសេសពីសហភាពអឺរ៉ុប ក្នុងការផ្តល់ហិរញ្ញប្បទានដល់មូលនិធិក្រុង ស្រុក ដើម្បីធានាថា ក្រុង ស្រុកនីមួយៗមានធនធានអភិវឌ្ឍន៍មូលដ្ឋានក្នុងកម្រិតសមស្របមួយជាបណ្តើរៗចាប់ពីឆ្នាំ២០១៦តទៅរហូតដល់ឆ្នាំ២០១៨ដែលអត្រា០,៥% នេះនឹងត្រូវរ៉ាប់រងបានដោយថវិការបស់រាជរដ្ឋាភិបាលផ្ទាល់។

យ៉ាងណាមិញ យោងស្ថានភាពជាក់ស្តែង យើងបានប្រមើលមើលឃើញថា អត្រា០,៥%នៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុកនេះ នឹងពុំសម្រេចបាននៅក្នុងឆ្នាំ២០១៨ នោះឡើយ។ ការពុំអាចសម្រេចបាននូវសូចនាករដ៏សំខាន់នេះដោយសារ ទី១.) សហភាពអឺរ៉ុបពុំមានថវិកាសម្រាប់គាំទ្រកម្មវិធីកំណែទម្រង់នៅក្នុងឆ្នាំ២០១៦ និងទី២.)ការកើនឡើងយ៉ាងខ្លាំងនូវប្រាក់បៀវត្ស របស់មន្ត្រីរាជការ ដែលស្រូបយកនូវចំណែកយ៉ាងធំពីមូលនិធិក្រុង ស្រុក។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏សហភាពអឺរ៉ុបនៅតែផ្តល់អាទិភាពយ៉ាងសំខាន់ទៅលើការបង្កើនសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុកនៅក្នុងការរៀបចំតាក់តែងកម្មវិធីថ្មីនេះ។

ផ្អែកលើស្ថានភាពខាងលើនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានគ្រោងស្នើសុំសហភាពអឺរ៉ុបនូវថវិកាចំនួនប្រមាណ**១២**លានដុល្លារសម្រាប់គាំទ្រដល់មូលនិធិក្រុង ស្រុកសម្រាប់រយៈពេល២ឆ្នាំ គឺឆ្នាំ២០១៧ ចំនួន**៤,៥**លានដុល្លារ និងឆ្នាំ២០១៨ចំនួន**៧,៥**លានដុល្លារ និងគ្រោងស្នើសុំការអនុញ្ញាតជាគោលការណ៍ពី គ.ជ.អ.ប ដើម្បីកែសម្រួលពេលវេលានៃការសម្រេចសូចនាករពាក់ព័ន្ធនឹងអត្រា០,៥%នៃសមាសភាគអភិវឌ្ឍន៍ ដែលត្រូវរ៉ាប់រងដោយរាជរដ្ឋាភិបាលផ្ទាល់ពីឆ្នាំ២០១៨ទៅឆ្នាំ២០១៩វិញ។ សំណើនេះ ត្រូវបានគ្រោងឡើងដោយផ្អែកទៅលើអត្រាភាគរយនៃសមាភាគអភិវឌ្ឍន៍មូលដ្ឋានរបស់មូលនិធិក្រុង ស្រុក ដែលកំពុងមាននិន្នាការថយចុះជាបន្តបន្ទាប់ គឺអត្រា**០,៣០%**នៅឆ្នាំ២០១៧ អត្រា**០,២៨%**នៅឆ្នាំ២០១៨ និងអត្រា**០,២៥%**នៅឆ្នាំ២០១៩ ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាងទី១៖អំពីស្ថានភាពនៃធនធានមូលនិធិក្រុង ស្រុកយោងតាមអនុក្រឹត្យ (គិតជាដុល្លារអាមេរិក)

ល.រ	បរិយាយ	២០១៦	២០១៧	២០១៨	២០១៩
១	ចំណូលចរន្តថវិកាជាតិ*	៣.៣១០.៤៣៥.៣០៩	៣.៨០៧.០០០.៤៩៨	៤.៣៧៨.០៥០.៦១៧	៥.០៣៨.៧៥៨.២១០
២	អត្រាចូលរួមពីថវិកាជាតិទៅក្នុងមូលនិធិក្រុង ស្រុក**	០,៩០%	១%	១%	១%
៣	ធនធានមូលនិធិក្រុង ស្រុកសរុប	២៤.៤៧៧.០៣៧	៣៣.១០៤.៣៥៣	៣៨.០៧០.០០៥	៤៣.៧៨០.៥០៦
	៣.១ សមាសភាគរដ្ឋបាលទូទៅ	១៩.៦១៣.១៦១	២៣.៣១៥.២៩៩	២៧.៥៨១.១០៦	៣២.៦៤០.៤៨៧
	ក. បន្ទុកបុគ្គលិក	១៨.៨០៧.២០០	២០.២២៤.០១៨	២៤.២៦៨.៨២២	២៩.១២២.៥៨៦
	ខ. ចំណាយប្រតិបត្តិការ ***	១.៥៣៥.៩៦០	៣.០៩១.២៨០	៣.៣១២.២៨៤	៣.៥១៧.៩០១
	៣.២ សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន**	៤.៨៦៣.៨៧៦	៩.៧៨៩.០៥៥	១០.៤៨៨.៨៩៩	១១.១៤០.០១៩
	ក. អត្រាភាគរយនៃថវិកាអភិវឌ្ឍន៍មូលដ្ឋានក្រុង ស្រុក*****	<u>0,១៨%</u>	<u>0,៣0%</u>	<u>0,២៨%</u>	<u>0,២៥%</u>
	ខ. ថវិកាអភិវឌ្ឍន៍មូលដ្ឋានជាមធ្យមក្នុងមួយក្រុង ស្រុក	<u>២៦.២៩១</u>	<u>៥២.៩១៤</u>	<u>៥៦.៦៩៧</u>	<u>៦0.២១៦</u>

សម្គាល់៖

** ការព្យាករណ៍ផ្អែកលើកំណើនសេដ្ឋកិច្ចក្នុងអត្រា១៥%ប្រចាំឆ្នាំ*

*** ផ្អែកតាមអនុក្រឹត្យស្តីលេខ៣៤២ អនក្របក. ស្តីពីការចូលរួមធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក*

**** ចំណាយប្រតិបត្តិការត្រូវបានគណនាតាមរូបមន្ត៖ ធនធានមូលនិធិសរុប ដក ចំនួនសរុបប្រាក់ឧបត្ថម្ភរបស់មាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក គុណនឹង ០,២៤%*

***** សមាសភាគអភិវឌ្ឍន៍មូលដ្ឋានក្រុង ស្រុកត្រូវបានគណនាតាមរូបមន្ត៖ ធនធានមូលនិធិក្រុង ស្រុកសរុប ដក ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាល (ជាទូទៅប្រាក់បៀវត្ស និងចំណាយប្រតិបត្តិការ)*

****** អត្រាភាគរយនៃថវិកាអភិវឌ្ឍន៍មូលដ្ឋានក្រុង ស្រុកសរុបធៀបនឹងចំណូលចរន្តថវិកាជាតិឆ្នាំកន្លងមក*

តារាងខាងក្រោមនេះបង្ហាញអំពីចំនួន និងអត្រានៃថវិការបស់ផ្នែកនានានៃមូលនិធិក្រុង ស្រុក ធៀបទៅនឹងមូលនិធិក្រុង ស្រុកជាមធ្យមរបស់ក្រុង ស្រុកនីមួយៗ។ តារាងនេះបានបង្ហាញថា បើទោះបីជាចំនួនថវិកាជាក់ស្តែងនៃមូលនិធិក្រុង ស្រុកជាមធ្យមសម្រាប់ក្រុង ស្រុកនីមួយៗ ក៏ដូចជាចំនួនថវិកាជាក់ស្តែងនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានមានការកើនឡើងក៏ដោយ ក៏ការចំណាយលើបន្ទុកបុគ្គលិករបស់ក្រុង ស្រុកនីមួយៗមានការកើនឡើងខ្លាំង ដោយបានស្រូបយកមូលនិធិនេះរហូតដល់៦១,០៩%នៅឆ្នាំ២០១៧ ៦៣,៧៥%នៅឆ្នាំ២០១៨ និង៦៦,៥២%នៅឆ្នាំ២០១៩។ ករណីនេះ បានធ្វើឱ្យភាគរយនៃសមាសភាគអភិវឌ្ឍមូលដ្ឋានមានការថយចុះជាបន្តបន្ទាប់ គឺមានតែ២៩,៥៧%នៅឆ្នាំ២០១៧ ២៧,៥៥% នៅឆ្នាំ២០១៨ និង២៥,៤៥%នៅឆ្នាំ២០១៩។

តារាងទី១៖ ចំនួន និងអត្រានៃថវិកាតាមផ្នែកនានានៃមូលនិធិក្រុង ស្រុកនីមួយៗ(គិតជាដុល្លារអាមេរិក)

ល.រ	បរិយាយ	២០១៦	២០១៧	២០១៨	២០១៩
	មូលនិធិក្រុង ស្រុកជាមធ្យមសម្រាប់ក្រុង ស្រុកនីមួយៗ	១៣២.៣០៨	១៧៨.៩៤២	២០៥.៧៨៣	២៣៦.៦៥១
១	បន្ទុកបុគ្គលិក: ចំនួនថវិកា អត្រាភាគរយ	៩៧.៧១៤ ៧៣,៨៥%	១០៩.៣១៩ ៦១,០៩%	១៣១.១៨២ ៦៣,៧៥%	១៥៧.៤១៩ ៦៦,៥២%
២	ប្រតិបត្តិការ ចំនួនថវិកា អត្រាភាគរយ	៨.៣០២ ៦,២៨%	១៦.៧០៩ ៩,៣៤%	១៧.៩០៤ ៨,៧០%	១៩.០១៥ ៨,០៤%
៣	**អភិវឌ្ឍន៍មូលដ្ឋាន** ចំនួនថវិកា អត្រាភាគរយ	**<u>២៦.២៩១</u>** **<u>១៩,៨៧%</u>**	**<u>៥២.៩១៣</u>** **<u>២៩,៥៧%</u>**	**<u>៥៦.៦៩៦</u>** **<u>២៧,៥៥%</u>**	**<u>៦០.២១៦</u>** **<u>២៥,៤៥%</u>**

ក្នុងករណីដែលមានការឯកភាពលើការចូលរួមចំណែកពីសហភាពអឺរ៉ុបទៅលើមូលនិធិក្រុង ស្រុកនូវចំនួនថវិកាដូចបានគ្រោងស្នើសុំខាងលើ គឺការចូលរួមចំណែកចំនួន**៤,៥**លានដុល្លារនៅឆ្នាំ២០១៧ និងចំនួន**៧,៥**លានដុល្លារនៅឆ្នាំ២០១៨ នោះនឹងធ្វើឱ្យអត្រាភាគរយនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានមាន

ការកើនឡើង ដែលក្នុងនោះ នៅឆ្នាំ២០១៧ មានអត្រា**0,៤0%** និងនៅក្នុងឆ្នាំ២០១៨មានអត្រា**0,៤៣%** (ចំនួនថវិកាសមាសភាគអភិវឌ្ឍន៍មូលដ្ឋានជាមធ្យមសម្រាប់ក្រុង ស្រុកនីមួយៗមានប្រមាណ**៧,១00** ដុល្លារនៅឆ្នាំ២០១៧ និង**៨,៧00**ដុល្លារនៅឆ្នាំ២០១៨)។ ទោះបីទាំងអត្រា និងទំហំទាំងនេះមានការកើនឡើងក៏ដោយ ក៏នៅមិនទាន់សម្រេចបានតាមសូចនាករដែលបានកំណត់ឡើយ(អត្រា0,៥0%)។ អាស្រ័យហេតុនេះ ដើម្បីធានាបាននូវនិន្នាការកើនឡើង និងសម្រេចបាននូវសូចនាកររនេះ លុះត្រាតែមានការបង្កើនបន្ថែមនូវការចូលរួមចំណែកពីថវិកាជាតិចំនួនប្រមាណ**១៣លាន**ដុល្លារនៅឆ្នាំ២០១៩ ដែលករណីទាំងនេះតម្រូវឱ្យមានការកែសម្រួលអនុក្រឹត្យលេខ៣៤២ អនក្រ.បក ស្តីពីការចូលរួមធនធានពីថវិកាជាតិដល់មូលនិធិក្រុង ស្រុក ដើម្បីបង្កើនធនធានចូលរួមពីថវិកាជាតិទៅក្នុងមូលនិធិក្រុង ស្រុកឱ្យបានអត្រា**១,១៤%**សម្រាប់ឆ្នាំ២០១៧ អត្រា**១,២0%**សម្រាប់ឆ្នាំ២០១៨ និងអត្រា**១,៣២%**សម្រាប់ឆ្នាំ២០១៩ ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម (ក្នុងករណីដែលមានការចូលរួមពីសហភាពអឺរ៉ុបសម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨)។

តារាងទី៣៖ ស្ថានភាពនៃធនធានមូលនិធិក្រុង ស្រុកដោយមានការគាំទ្រពីសហភាពអឺរ៉ុប (គិតជាដុល្លារ)

លរ.	បរិយាយ	២០១៦	២០១៧	២០១៨	២០១៩
១	ចំណូលចរន្តថវិកាជាតិ*	៣.៣១0.៤៣៥.៣0៩	៣.៨0៧.000.៤៩៤	៤.៣៧៨.0៥0.៦១៧	៥.0៣៤.៧៥៨.២១0
២	អត្រាចូលរួមពីថវិកាទៅក្នុងមូលនិធិក្រុង ស្រុក	0,៩0%	១,១៤%	១,២0%	១,៣២%
៣	**ធនធានថវិកាដែលអាចមាន** ក. ថវិការដ្ឋ** ខ. ថវិកាសហភាពអឺរ៉ុប	២៤.៤៧៧.0៣៧ 0,00	៣៣.១0៤.៣៥៣ ៤.៥00.000	៣៨.0៧0.00៥ ៧.៥00.000	៥៧.៧៩0.២៦៨ 0,00
៤	ធនធានមូលនិធិក្រុង ស្រុកសរុប	២៤.៤៧៧.0៣៧	៣៧.៦0៤.៣៥៣	៤៥.៥៧0.00៥	៥៧.៧៩0.២៦៨
	៤.១ សមាសភាគរដ្ឋបាលទូទៅ	១៩.៦១៣.១៦១	២៤.៣៩៥.២៩៩	២៩.៣៨១.១0៦	៣៦.00២.៨៣0
	ក. បន្ទុកបុគ្គលិក	១៩.៦១៣.១៦១	២៤.៣៩៥.២៩៩	២៩.៣៨១.១0៦	៣៦.00២.៨៣0
	ខ. ចំណាយប្រតិបត្តិការ ***	១.៥៣៥.៩៦0	៤.១៧១.២៨0	៥.១១២.២៨៤	៦.៨៨0.២៤៤
	៤២. សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន****	៤.៨៦៣.៨៧៦	១៣.២0៩.0៥៥	១៦.១៨៨.៨៩៩	២១.៧៨៧.៤៣៨
	ក. អត្រាភាគរយនៃថវិកាអភិវឌ្ឍន៍មូលដ្ឋានក្រុង ស្រុក*****	0,១៨%	0,៤0%	0,៤៣%	0,៥0%
	ខ. ថវិកាអភិវឌ្ឍន៍មូលដ្ឋានជាមធ្យមក្នុងមួយក្រុង ស្រុក	២៦.២៩១	៧១.៤00	៨៧.៥0៨	១១៧.៧៧0

- **ការគាំទ្រក្នុងលក្ខណៈជាវិធានការបំពេញបន្ថែម** មានចំនួនប្រមាណ**៦លាន**ដុល្លារ

ក្រៅពីការគាំទ្រដល់សកម្មភាពស្នូលនៃកម្មវិធីកំណែទម្រង់ និងមូលនិធិក្រុង ស្រុក កម្មវិធីនេះនឹងរៀបចំឱ្យមានជាការគាំទ្រក្នុងលក្ខណៈជាវិធានការបំពេញបន្ថែម ដែលគ្រោងថវិកាចំនួនប្រមាណ**៦លាន**ដុល្លារ ពោលគឺប្រមាណ**១,៥លាន**ដុល្លារក្នុង១ឆ្នាំ។ ថវិកានេះនឹងត្រូវគ្រប់គ្រងដោយសហភាពអឺរ៉ុបដែលត្រូវផ្តល់ការគាំទ្រទៅឱ្យភ្នាក់ងារអនុវត្តនានា (អាចជាស្ថាប័នរដ្ឋ ឬអង្គការអន្តរជាតិណាមួយដែលបានរៀបចំគម្រោងស្នើសុំទៅសហភាពអឺរ៉ុបដោយផ្តោតជាសំខាន់ទៅលើការគាំទ្រដល់ការផ្សេរមុខងារ ព្រមទាំងការងារសំខាន់ផ្សេងទៀតនៃកម្មវិធីកំណែទម្រង់ដែលពុំស្ថិតនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

របស់ គ.ជ.អ.ប)។ ថវិកានេះក៏នឹងគ្រោងប្រើប្រាស់ទៅលើការគាំទ្របច្ចេកទេសចាំបាច់មួយចំនួន ដូចជា ការត្រួតពិនិត្យ វាយតម្លៃ ការធ្វើសវនកម្មផងដែរ។

តារាងខាងក្រោមសង្ខេបអំពីសំណើគម្រោងថវិកាសម្រាប់សមាសភាគនីមួយៗក្នុងចំនួនថវិកាប្រមាណ**៤៧លាន**ដុល្លារពីសហភាពអឺរ៉ុបសម្រាប់ដំណាក់កាលទី១ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០។

តារាងទី៨៖ គម្រោងថវិកាតាមសមាសភាគនីមួយៗនៃកម្មវិធី (គិតជាលានដុល្លារអាមេរិក)

សមាសភាគ	២០១៧	២០១៨	២០១៩	២០២០	សរុប
ការគាំទ្រសកម្មភាពស្នូល	៩	៧	៧	៦	**២៩**
ការគាំទ្រមូលនិធិក្រុង ស្រុក	៤,៥	៧,៥	០	០	**១២**
វិធានការបំពេញបន្ថែម	១,៥	១,៥	១,៥	១,៥	**៦**
សរុប	**១៥**	**១៦**	**៨,៥**	**៧,៥**	**៤៧**

ផ្អែកលើរបាយការណ៍ខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប គោរពស្នើសុំគោលការណ៍ដូចតទៅ៖

១. ស្នើសុំក្សាសូចនាករពាក់ព័ន្ធនឹងការបង្កើនថវិកានៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានរបស់មូលនិធិក្រុង ស្រុកឱ្យបានយ៉ាងតិច០,៥%ធៀបទៅនឹងចំណូលចរន្តនៃថវិកាជាតិដដែល ក៏ប៉ុន្តែស្នើសុំកែសម្រួលពេលវេលានៃការសម្រេចសូចនាករនេះដែលគ្រោងសម្រេចឱ្យបានពីឆ្នាំ២០១៨ទៅឆ្នាំ២០១៩វិញ

២. ស្នើសុំគោលការណ៍អនុញ្ញាតឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប បន្តពិភាក្សាជាមួយមន្ត្រីសហភាពអឺរ៉ុបទៅលើការរៀបចំតាក់តែងកម្មវិធីគាំទ្ររបស់សហភាពអឺរ៉ុបដែលផ្អែកទៅលើការគ្រោងរៀបចំជាដំណាក់កាល ចំនួន ថវិកា និងសមាសភាគនៃកម្មវិធីដូចបានគោរពរាយការណ៍ជូនខាងលើ

៣. ស្នើសុំរៀបចំលិខិតពី គ.ជ.អ.ប ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យមើលលទ្ធភាពក្នុងការកែសម្រួលអនុក្រឹត្យលេខ៣៤២ អនក្រ.បក ស្តីពីការចូលរួមធនធានពីថវិកាជាតិដល់មូលនិធិក្រុង ស្រុក ក្នុងករណីដែលមានការឯកភាពពីសហភាពអឺរ៉ុបក្នុងការចូលរួមគាំទ្រដល់មូលនិធិក្រុង ស្រុកចាប់ពីឆ្នាំ២០១៧តទៅ។ សំណើកែសម្រួលអនុក្រឹត្យនេះ អាចនឹងប៉ះពាល់ទៅលើអត្រាកាគរយនៃការចូលរួមពីថវិកាជាតិដល់មូលនិធិក្រុង ស្រុកចាប់ពីឆ្នាំ២០១៧តទៅ ដើម្បីធានាថា នៅឆ្នាំ២០១៩ (ជាឆ្នាំដែលរាជរដ្ឋាភិបាលត្រូវរ៉ាប់រងដោយខ្លួនឯង) អត្រានៃការចូលរួមធនធានពីថវិកាជាតិដល់មូលនិធិក្រុង ស្រុកនឹងត្រូវបានបង្កើនពីចំនួន១%ទៅ១,៣២% (មានន័យថា រាជរដ្ឋាភិបាលត្រូវគ្រោងបន្ថែមថវិកាចំនួនប្រមាណ**១៣លាន**ដុល្លារទៅលើមូលនិធិក្រុង ស្រុកតែសម្រាប់ឆ្នាំ២០១៩តែប៉ុណ្ណោះ)។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាពិនិត្យ និងផ្តល់គោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

អនុប្រធានប្រតិបត្តិ